**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រ.ក/លេខ០១០.០២៨/០៧ គជប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៧

# គ្រប់ខេត្ត ក្រុង ត្រូវផ្តល់អាទិភាពដល់ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំមួយ លេខ ១១៧៤ ស.ជ.ណ ទៅគ្រប់អភិបាលខេត្ត ក្រុងឱ្យផ្តល់ពេលវេលាជាអាទិភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ក្នុងការបំពេញការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ តាមប្រតិទិនកំណត់របស់ គ.ជ.ប ។

ក្រសួងមហាផ្ទៃបានកត់សំគាល់ឃើញថា ការខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ បានធ្វើឱ្យសំរេចនូវលទ្ធផលល្អបង្គួរក្នុងជំហ៊ានដំបូងនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ដើម្បីជំរុញ និងបង្កលក្ខណៈឱ្យកាន់តែងាយស្រួលថែមទៀតក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងរក្សាបាននូវនិរន្តរភាពការងាររបស់ឃុំ សង្កាត់ ក្រសួងមហាផ្ទៃបានណែនាំឱ្យគ្រប់ខេត្ត ក្រុង ត្រូវចាត់ទុកការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជាភារកិច្ចអាទិភាពមួយក្នុងចំណោមភារកិច្ចសំខាន់ៗរបស់ខេត្ត ក្រុង ។

ក្រសួងក៏បានណែនាំដល់គ្រប់ខេត្ត ក្រុង ត្រូវផ្អាកជាបណ្តោះអាសន្ននូវរាល់កិច្ចប្រជុំ ឬសិក្ខាសាលា ដែលនាំឱ្យមានការរាំងស្ទះដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ( ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ) ។ លើសពីនេះទៀតក្រសួងមហាផ្ទៃក៏បានណែនាំឱ្យខេត្ត ក្រុង ត្រូវតាមដាន និងត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំ និងដោះស្រាយឱ្យបានទាន់ពេលវេលារាល់ការលំបាក់ទាំងឡាយរបស់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយធ្វើកិច្ចសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមគ្រប់លំដាប់ថ្នាក់ឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

BtmanbEnmsmTnakTngTrsBe l x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh